ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ០៩៩/២៨ កសក

# ប្រកាស
# ស្តីពី
# នីតិវិធីនៃការត្រួតពិនិត្យដើមគ្រា និងការផ្តល់សុពលភាពផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្មនិងជីកសិកម្ម

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៥ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឲ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឲ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលំអដីកសិកម្មទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ



អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ :(០២៣) ៧២៦ ១២៨/ ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
N° 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
Phone : (023) 726 128 / 726 129. Fax : (855) 23 - 217 320

- បានឃើញប្រកាសលេខ១១៩ ប្រក.កសក ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៣ ស្តីពីនីតិវិធីនៃការគ្រប់គ្រងជីកសិកម្ម ដែលត្រូវធ្វើពាណិជ្ជកម្ម
- បានឃើញប្រកាសលេខ១២០ប្រក.កសក ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៣ ស្តីពីនីតិវិធីនៃការគ្រប់គ្រងថ្នាំកសិកម្មដែលត្រូវធ្វើពាណិជ្ជកម្ម
- បានឃើញប្រកាសលេខ១៧៦ ប្រក.កសក ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីនីតិវិធីនៃការធ្វើអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម
- បានឃើញប្រកាសអន្តរក្រសួងលេខ៩៦ កយ.កសក.ប្រក/១៣ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៣ ស្តីពីការផ្តល់នីតិសម្បទាជានគរបាលយុត្តិធម៌
- បានឃើញប្រកាសលេខ១៩៩ ប្រក.កសក ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៤ ស្តីពីនីតិវិធីនិងសិទ្ធិពិន័យអន្តរការណ៍លើបទល្មើសដែលបានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងធានាគុណភាព ប្រសិទ្ធភាព និងសុវត្ថិភាពនៃថ្នាំកសិកម្មនិងជីកសិកម្មដែលត្រូវនាំចូលនាំចេញ ឬត្រូវលាយផ្សំឬវេចខ្ចប់ជាថ្មី និងធានាអនុវត្តការតម្រូវបមាណីយសម្រាប់ផលិតផលថ្នាំកសិកម្មនិងជីកសិកម្មដែលត្រូវធ្វើពាណិជ្ជកម្ម នៅមុនពេលផ្គត់ផ្គង់ចែកចាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីការពារផលប្រយោជន៍របស់កសិករនិងអ្នកប្រើប្រាស់ចុងក្រោយនៅក្នុងផលិតកម្មកសិកម្ម ឬសម្រាប់ការនាំចេញពីព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២.-**

ប្រកាសនេះមានគោលដៅ៖

- កំណត់នីតិវិធីនៃការត្រួតពិនិត្យដើមគ្រា និងការផ្តល់សុពលភាពផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្មនិងជីកសិកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយអនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម

- ផ្តល់នូវគោលការណ៍រួមនិងនីតិវិធីឯកភាពសម្រាប់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមានសមត្ថកិច្ច ដើម្បីអនុវត្តនៅក្នុងប្រតិបត្តិការអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មដែលធ្វើពាណិជ្ជកម្មនាំចូលនាំចេញ លាយផ្សំឬវេចខ្ចប់ជាថ្មី នៅមុនពេលផ្គត់ផ្គង់ចែកចាយសម្រាប់ការប្រើប្រាស់ក្នុងផលិតកម្មកសិកម្ម ឬសម្រាប់ការនាំចេញពីព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៣.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះថ្នាំកសិកម្មនិងជីកសិកម្មគ្រប់ប្រភេទ ដែលត្រូវធ្វើការនាំចូលនាំចេញ ការលាយផ្សំ ការវេចខ្ចប់ជាថ្មី នៅមុនពេលផ្គត់ផ្គង់ចែកចាយសម្រាប់ការប្រើប្រាស់នៅក្នុងផលិតកម្មកសិកម្ម ឬសម្រាប់ការនាំចេញពីព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២
## សមត្ថកិច្ច

**ប្រការ ៤.-**

នាយកដ្ឋាននីតិកម្មកសិកម្ម ជាអង្គភាពមានសមត្ថកិច្ចធ្វើការត្រួតពិនិត្យដើមគ្រា។ នាយកដ្ឋាននីតិកម្មកសិកម្ម ផ្តល់សុពលភាពផ្គត់ផ្គង់ចែកចាយ នូវថ្នាំកសិកម្មឬជីកសិកម្មដែលធ្វើប្រតិបត្តិការពាណិជ្ជកម្មនាំចូលនាំចេញ លាយផ្សំឬវេចខ្ចប់ជាថ្មី នៅក្នុងព្រះរាជាណាចក្រកម្ពុជាឬសម្រាប់ការនាំចេញពីព្រះរាជាណាចក្រកម្ពុជា បន្ទាប់ពីទទួលបានការឯកភាពពីរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**ប្រការ ៥.-**

មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មនៃនាយកដ្ឋាននីតិកម្មកសិកម្ម ដែលមាននីតិសម្បទាជានគរបាលយុត្តិធម៌ បំពេញភារកិច្ច និងមានសមត្ថកិច្ចធ្វើការត្រួតពិនិត្យដើមគ្រាថ្នាំកសិកម្មឬជីកសិកម្ម ដោយអនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម បទដ្ឋានគតិយុត្តពាក់ព័ន្ធ និងប្រកាសនេះ។

## ជំពូកទី៣
## នីតិវិធីនៃការត្រួតពិនិត្យដើមគ្រានិងការផ្តល់សុពលភាព ផ្គត់ផ្គង់ចែកចាយ

### ផ្នែកទី១៖ នីតិវិធីរួម

**ប្រការ ៦.-**

រាល់ផលិតផលថ្នាំកសិកម្មឬជីកសិកម្ម ដែលត្រូវធ្វើការផ្គត់ផ្គង់ចែកចាយ នាំចូលនាំចេញ លាយផ្សំ ឬវេចខ្ចប់ជាថ្មី ចាំបាច់ត្រូវឆ្លងកាត់នីតិវិធីនៃការត្រួតពិនិត្យដើមគ្រានិងការផ្តល់សុពលភាពផ្គត់ផ្គង់ចែកចាយ ដោយអនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម បទដ្ឋានគតិយុត្តពាក់ព័ន្ធ និងប្រកាសនេះ។

**ប្រការ ៧.-**

ប្រតិបត្តិករដែលធ្វើការនាំចូលនាំចេញ ធ្វើការលាយផ្សំ ឬធ្វើការវេចខ្ចប់ជាថ្មីនូវផលិតផលថ្នាំកសិកម្ម ឬជីកសិកម្ម ត្រូវធ្វើលិខិតប្រតិវេទន៍ជាចាំបាច់ជូននាយកដ្ឋាននីតិកម្មកសិកម្ម នូវផលិតផលដែលត្រូវធ្វើការនាំចូលនាំចេញ ធ្វើការលាយផ្សំឬការវេចខ្ចប់ជាថ្មី ដោយភ្ជាប់ជាមួយនូវឯកសារពាក់ព័ន្ធ។

ផលិតផលថ្នាំកសិកម្មឬជីកសិកម្មដែលត្រូវធ្វើប្រតិវេទន៍ នៅពេលធ្វើការនាំចូលនាំចេញ ការលាយផ្សំឬវេចខ្ចប់ជាថ្មី ត្រូវដកយកសំណាកដើម្បីធ្វើវិភាគផ្ទៀងផ្ទាត់និងត្រូវធ្វើការត្រួតពិនិត្យលើការអនុវត្តការតម្រូវបមាណីយ និងកាតព្វកិច្ចផ្សេងទៀតរបស់ប្រតិបត្តិករ ដើម្បីទទួលបានសុពលភាពផ្គត់ផ្គង់ចែកចាយ ឬធ្វើការនាំចេញ ស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មជាធរមាន។

**ប្រការ ៨.-**

លិខិតប្រតិវេទន៍ត្រូវមានខ្លឹមសារដូចខាងក្រោម៖

- អត្តសញ្ញាណក្រុមហ៊ុនឬប្រតិបត្តិករដែលធ្វើប្រតិវេទន៍
- យថាប្រភេទ បរិមាណនៃថ្នាំកសិកម្មឬជីកសិកម្មដែលត្រូវធ្វើប្រតិបត្តិការ
- មាត់ច្រក កំពង់ផែដែលត្រូវធ្វើប្រតិបត្តិការនាំចូលនាំចេញ
- ទីតាំងនិងអាសយដ្ឋានគ្រឹះស្ថានលាយផ្សំឬវេចខ្ចប់ជាថ្មីផលិតផលថ្នាំកសិកម្មឬជីកសិកម្ម
- ចំនួនទីតាំងនិងអាសយដ្ឋានឃ្លាំងសន្និធិថ្នាំកសិកម្មឬជីកសិកម្មដែលត្រូវធ្វើប្រតិវេទន៍
- ប្រភេទ ចំនួន មធ្យោបាយដឹកជញ្ជូនដែលមានអត្តសញ្ញាណច្បាស់លាស់
- កាលបរិច្ឆេទ ពេលវេលាដែលមធ្យោបាយដឹកជញ្ជូនថ្នាំកសិកម្មឬជីកសិកម្មមកដល់ ឬនឹងត្រូវដឹកចេញពីឃ្លាំងសន្និធិដែលត្រូវត្រួតពិនិត្យ។

គំរូលិខិតប្រតិវេទន៍លើប្រតិបត្តិការពាក់ព័ន្ធនឹងថ្នាំកសិកម្មឬជីកសិកម្ម ត្រូវបានកំណត់នៅក្នុងឧបសម្ពន្ធទី១នៃប្រកាសនេះ។

**ប្រការ ៩.-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលធ្វើប្រតិវេទន៍ អំពីប្រតិបត្តិការពាក់ព័ន្ធថ្នាំកសិកម្មឬជីកសិកម្ម មានកាតព្វកិច្ច ដូចខាងក្រោម៖

១- ត្រូវអនុញ្ញាតនិងផ្តល់កិច្ចសហការឲ្យមន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមានសមត្ថកិច្ចធ្វើការត្រួតពិនិត្យ។

២- ត្រូវបង្ហាញលិខិតអនុញ្ញាតនិងវិញ្ញាបនបត្រពាក់ព័ន្ធប្រតិបត្តិការរបស់ខ្លួន លិខិតប្រតិវេទន៍កំណត់ត្រាពាណិជ្ជកម្មតាមប្រតិបត្តិការនីមួយៗ និងឯកសារពាក់ព័ន្ធផ្សេងទៀត តាមការតម្រូវ ដោយអនុលោមតាមនីតិវិធីនៃប្រកាសនេះ។

៣- ត្រូវឆ្លើយបំភ្លឺ ពន្យល់ និងផ្តល់ព័ត៌មានឬឯកសារពាក់ព័ន្ធនឹងប្រតិបត្តិការ ថ្នាំកសិកម្មឬជីកសិកម្មដែលត្រូវធ្វើប្រតិវេទន៍។

៤- ត្រូវបំពេញឬឆ្លើយតបនឹងបញ្ជីសំណួរ របស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មពាក់ព័ន្ធនឹងប្រតិបត្តិការថ្នាំកសិកម្មឬជីកសិកម្មដែលត្រូវធ្វើប្រតិវេទន៍។

៥- ត្រូវផ្តល់សំណាកថ្នាំកសិកម្មឬជីកសិកម្មសម្រាប់ការធ្វើវិភាគផ្ទៀងផ្ទាត់ និងចូលរួមបំពេញសំណុំបែបបទនៅក្នុងដំណើរការត្រួតពិនិត្យ។

៦- ត្រូវបំពេញកាតព្វកិច្ចផ្សេងទៀតក្នុងក្របខ័ណ្ឌ នៃការត្រួតពិនិត្យដើមគ្រាថ្នាំកសិកម្មឬជីកសិកម្ម ដោយអនុលោមតាមបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងប្រកាសនេះ។

### ប្រការ ១០.-

គំរូកំណត់ត្រាពាណិជ្ជកម្មថ្នាំកសិកម្មឬជីកសិកម្មតាមប្រតិបត្តិការនីមួយៗ ត្រូវបានកំណត់ដោយឧបសម្ពន្ធទី២នៃប្រកាសនេះ។

គំរូបញ្ជីសំណួរសម្រាប់ការត្រួតពិនិត្យដើមគ្រានូវផលិតផលថ្នាំកសិកម្មឬជីកសិកម្ម ត្រូវកំណត់ដោយនាយកដ្ឋាននីតិកម្មកសិកម្ម។

## ផ្នែកទី២៖ នីតិវិធីត្រួតពិនិត្យដើមគ្រាលើផលិតផលនាំចូល

### ប្រការ ១១.-

ប្រតិបត្តិករដែលកាន់កាប់លិខិតអនុញ្ញាតនាំចូលថ្នាំកសិកម្មឬជីកសិកម្ម មានកាតព្វកិច្ច ធ្វើលិខិតប្រតិវេទន៍ជូននាយកដ្ឋាននីតិកម្មកសិកម្ម អំពីការនាំចូលមកដល់នៅក្នុងឃ្លាំងអចិន្ត្រៃយ៍របស់ប្រតិបត្តិករ នៅក្នុងរយៈពេលយ៉ាងតិច **១៥** (ដប់ប្រាំ)ថ្ងៃ មុនថ្ងៃនាំចូលជាក់ស្តែង។

នាយកដ្ឋាននីតិកម្មកសិកម្ម ត្រូវចាត់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមានសមត្ថកិច្ចនៅក្នុងរយៈពេលមិនលើសពី **៥** (ប្រាំ)ថ្ងៃ ដោយគិតចាប់ពីថ្ងៃទទួលលិខិតប្រតិវេទន៍ ដើម្បីចុះធ្វើការត្រួតពិនិត្យដើមគ្រាចំពោះផលិតផលថ្នាំកសិកម្មឬជីកសិកម្មដែលប្រតិបត្តិករធ្វើការនាំចូលជាក់ស្តែង។

ក្នុងករណីប្រតិបត្តិករមិនធ្វើប្រតិវេទន៍អំពីស្ថានភាពនៃការនាំចូលផលិតផលរបស់ខ្លួន មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមានសមត្ថកិច្ច ត្រូវចុះធ្វើការត្រួតពិនិត្យដើមគ្រា និងត្រូវចាត់វិធានការអនុវត្តច្បាប់តាមនីតិវិធី។

### ប្រការ ១២.-

ប្រតិបត្តិករដែលខកខានក្នុងការធ្វើប្រតិបត្តិការនាំចូលថ្នាំកសិកម្មឬជីកសិកម្ម ត្រូវធ្វើលិខិតជូនដំណឹងជូននាយកដ្ឋាននីតិកម្មកសិកម្ម អំពីស្ថានភាពខកខាននៃការនាំចូលផលិតផលរបស់ខ្លួន នៅក្នុងរយៈពេលយ៉ាងយូរ **៣** (បី)ខែ ដោយគិតចាប់ពីកាលបរិច្ឆេទចេញលិខិតអនុញ្ញាតនាំចូល។

ក្នុងករណីប្រតិបត្តិករមិនធ្វើប្រតិវេទន៍អំពីស្ថានភាពខកខាននៃការនាំចូលផលិតផលរបស់ខ្លួន នៅក្នុងរយៈពេល **៣** (បី)ខែ ដោយគិតចាប់ពីកាលបរិច្ឆេទនៃការចេញលិខិតអនុញ្ញាតនាំចូល មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមានសមត្ថកិច្ច ត្រូវចុះធ្វើការត្រួតពិនិត្យ និងត្រូវចាត់វិធានការអនុវត្តច្បាប់តាមនីតិវិធី។

### ប្រការ ១៣.-

នៅក្នុងការត្រួតពិនិត្យដើមគ្រា ចំពោះថ្នាំកសិកម្មឬជីកសិកម្មដែលនាំចូល មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមានសមត្ថកិច្ចមានសិទ្ធិនិងភារកិច្ច ដូចខាងក្រោម៖

១- ត្រួតពិនិត្យឯកសារពាក់ព័ន្ធ៖

- លិខិតអនុញ្ញាតនាំចូលថ្នាំកសិកម្មឬជីកសិកម្ម
- វិញ្ញាបនបត្របញ្ជាក់បញ្ជិកាផលិតផលថ្នាំកសិកម្មឬជីកសិកម្មដែលត្រូវធ្វើការនាំចូល
- វិញ្ញាបនបត្របញ្ជាក់លទ្ធផលវិភាគបមាណីយធាតុនៃជីកសិកម្មចេញពីប្រទេសប្រភពដើមនាំចេញ នៅពេលផ្ទុកទំនិញនាំចេញមកព្រះរាជាណាចក្រកម្ពុជា

- កំណត់ត្រាពាណិជ្ជកម្មថ្នាំកសិកម្មឬជីកសិកម្មប្រភេទ "ក" ស្តីពីប្រតិបត្តិការនាំចូលស្របតាមគំរូដែលដាក់ឲ្យប្រើប្រាស់
- ឯកសារពាក់ព័ន្ធប្រតិបត្តិការនាំចូល រួមមានៈ ឯកសារនាវានិងការដឹកជញ្ជូន ឯកសារបញ្ជីទំនិញ(Packing List) វិក្កយបត្រទំនិញ(Invoice) និងកិច្ចសន្យាផ្គត់ផ្គង់ផលិតផលថ្នាំកសិកម្មឬជីកសិកម្មរវាងក្រុមហ៊ុននាំចូលជាមួយក្រុមហ៊ុននាំចេញពីបរទេស
- ឯកសាររបស់អាជ្ញាធរគយនិងរដ្ឋាករកម្ពុជា បញ្ជាក់អំពីការបញ្ចេញទំនិញពីគយ
- ឯកសារបញ្ចូលឃ្លាំង បញ្ចេញឃ្លាំងផលិតផលថ្នាំកសិកម្មឬជីកសិកម្ម ដែលមានព័ត៌មានបញ្ជាក់អំពីប្រភពដើម និងទិសដៅផ្គត់ផ្គង់ចែកចាយច្បាស់លាស់
- ឯកសារពាក់ព័ន្ធផ្សេងទៀត តាមការតម្រូវរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

២- ត្រួតពិនិត្យការអនុវត្តការតម្រូវបមាណីយ ចំពោះផលិតផលថ្នាំកសិកម្មឬជីកសិកម្មដែលនាំចូល ដោយផ្ទៀតផ្ទាត់ជាមួយទិន្នន័យនិងព័ត៌មានដែលប្រតិបត្តិករបានអះអាងនៅពេលធ្វើការចុះបញ្ជី រួមមានៈ

- សំបកវេចខ្ចប់ និងស្លាកសញ្ញាព័ត៌មានជាភាសាខ្មែរ ដែលត្រូវអនុលោមតាមការតម្រូវបមាណីយ
- បមាណីយគុណភាពនៃផលិតផលថ្នាំកសិកម្មឬជីកសិកម្មដែលនាំចូល ដោយត្រូវដកយកសំណាកដើម្បីវិភាគផ្ទៀងផ្ទាត់បមាណីយដើមដែលបានអះអាង
- ការអនុវត្តវិធានសុវត្ថិភាពសម្រាប់ឃ្លាំងសន្និធិ និងការអនុវត្តវិធានបច្ចេកទេសសម្រាប់ការធ្វើសន្និធិថ្នាំកសិកម្មឬជីកសិកម្ម
- វត្តមាននិងការទទួលខុសត្រូវរបស់បុគ្គលិកបច្ចេកទេសប្រចាំការនៅគ្រឹះស្ថាននាំចូល និងនៅក្នុងឃ្លាំងសន្និធិផលិតផលថ្នាំកសិកម្មឬជីកសិកម្មរបស់ក្រុមហ៊ុន។

## ផ្នែកទី៣ៈ នីតិវិធីត្រួតពិនិត្យដើមគ្រាលើផលិតផលលាយផ្សំ ឬវេចខ្ចប់ជាថ្មី

**ប្រការ ១៤.-**

ប្រតិបត្តិករដែលកាន់កាប់លិខិតអនុញ្ញាតធ្វើប្រតិបត្តិការលាយផ្សំឬវេចខ្ចប់ជាថ្មី នូវថ្នាំកសិកម្មឬជីកសិកម្ម មានកាតព្វកិច្ចធ្វើលិខិតប្រតិវេទន៍ជូននាយកដ្ឋាននីតិកម្មកសិកម្ម អំពីផលិតផលថ្នាំកសិកម្មឬជីកសិកម្មដែលបានមកពីការលាយផ្សំឬវេចខ្ចប់ជាថ្មី នៅក្នុងឃ្លាំងអចិន្ត្រៃយ៍នៃគ្រឹះស្ថានលាយផ្សំឬវេចខ្ចប់ជាថ្មីរបស់ប្រតិបត្តិករ ចំនួនយ៉ាងតិច ២ (ពីរ)ដងក្នុងមួយឆ្នាំ។

នាយកដ្ឋាននីតិកម្មកសិកម្ម ត្រូវចាត់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមានសមត្ថកិច្ចនៅក្នុងរយៈពេលមិនលើសពី ៥ (ប្រាំ)ថ្ងៃ ដោយគិតចាប់ពីថ្ងៃទទួលលិខិតប្រតិវេទន៍ ដើម្បីចុះធ្វើការត្រួតពិនិត្យដើមគ្រាចំពោះផលិតផលថ្នាំកសិកម្មឬជីកសិកម្មដែលចេញពីប្រតិបត្តិការលាយផ្សំឬវេចខ្ចប់ជាថ្មីរបស់ក្រុមហ៊ុនដែលធ្វើប្រតិវេទន៍។

ក្នុងករណីប្រតិបត្តិករមិនធ្វើប្រតិវេទន៍អំពីផលិតផលថ្នាំកសិកម្មឬជីកសិកម្ម ដែលបានមកពីការលាយផ្សំឬវេចខ្ចប់ជាថ្មី នៅក្នុងឃ្លាំងអចិន្ត្រៃយ៍នៃគ្រឹះស្ថានលាយផ្សំឬវេចខ្ចប់ជាថ្មីរបស់ប្រតិបត្តិករ មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមានសមត្ថកិច្ច ត្រូវចុះធ្វើការត្រួតពិនិត្យដើមគ្រា និងត្រូវចាត់វិធានការអនុវត្តច្បាប់តាមនីតិវិធី។

**ប្រការ ១៥.–**

ប្រតិបត្តិករដែលខកខានក្នុងការធ្វើប្រតិបត្តិការលាយផ្សំឬវេចខ្ចប់ជាថ្មី នូវផលិតផលថ្នាំកសិកម្មឬជីកសិកម្ម ត្រូវធ្វើលិខិតជូនដំណឹងជូននាយកដ្ឋាននីតិកម្មកសិកម្ម អំពីស្ថានភាពខកខាននៃប្រតិបត្តិការរបស់ខ្លួន នៅក្នុងរយៈពេលយ៉ាងយូរ ៦ (ប្រាំមួយ)ខែម្តង ដោយគិតចាប់ពីកាលបរិច្ឆេទចេញលិខិតអនុញ្ញាតឲ្យធ្វើប្រតិបត្តិការលាយផ្សំឬវេចខ្ចប់ជាថ្មី។

ក្នុងករណីប្រតិបត្តិករមិនធ្វើប្រតិវេទន៍ អំពីស្ថានភាពខកខាននៃប្រតិបត្តិការលាយផ្សំឬវេចខ្ចប់ជាថ្មីរបស់ខ្លួននៅក្នុងរយៈពេល ៦ (ប្រាំមួយ)ខែ ដោយគិតចាប់ពីកាលបរិច្ឆេទនៃការចេញលិខិតអនុញ្ញាតធ្វើប្រតិបត្តិការលាយផ្សំឬវេចខ្ចប់ជាថ្មី មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមានសមត្ថកិច្ច ត្រូវចុះធ្វើការត្រួតពិនិត្យ និងចាត់វិធានការអនុវត្តច្បាប់តាមនីតិវិធី។

**ប្រការ ១៦.–**

នៅក្នុងការត្រួតពិនិត្យដើមគ្រា ចំពោះថ្នាំកសិកម្មឬជីកសិកម្មដែលចេញពីប្រតិបត្តិការលាយផ្សំឬវេចខ្ចប់ជាថ្មី មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមានសមត្ថកិច្ចមានសិទ្ធិនិងភារកិច្ច ដូចខាងក្រោម៖

១- ត្រួតពិនិត្យឯកសារពាក់ព័ន្ធ៖

- លិខិតអនុញ្ញាតធ្វើប្រតិបត្តិការលាយផ្សំឬវេចខ្ចប់ជាថ្មីនូវថ្នាំកសិកម្មឬជីកសិកម្ម
- វិញ្ញាបនបត្របញ្ជាក់បញ្ជីកាផលិតផលថ្នាំកសិកម្មឬជីកសិកម្មដែលត្រូវធ្វើការលាយផ្សំឬវេចខ្ចប់ជាថ្មី
- កំណត់ត្រាពាណិជ្ជកម្មថ្នាំកសិកម្មឬជីកសិកម្មប្រភេទ "ខ" ស្តីពីប្រតិបត្តិការលាយផ្សំឬវេចខ្ចប់ជាថ្មីនូវថ្នាំកសិកម្មឬជីកសិកម្ម ស្របតាមគំរូដែលដាក់ឲ្យប្រើប្រាស់
- ឯកសារពាក់ព័ន្ធប្រតិបត្តិការនាំចូលវត្ថុធាតុដើម រួមមាន៖ ឯកសារនាវានិងការដឹកជញ្ជូន ឯកសារបញ្ជីទំនិញ(Packing List) វិក្កយបត្រទំនិញ(Invoice) និងឯកសាររបស់អាជ្ញាធរគយនិងរដ្ឋាករកម្ពុជាពាក់ព័ន្ធការនាំចូលវត្ថុធាតុដើម
- ឯកសារបញ្ចូលឃ្លាំង បញ្ចេញឃ្លាំងផលិតផលថ្នាំកសិកម្មឬជីកសិកម្ម ដែលមានព័ត៌មានបញ្ជាក់អំពីប្រភពដើម និងទិសដៅផ្គត់ផ្គង់ចែកចាយច្បាស់លាស់
- ឯកសារពាក់ព័ន្ធផ្សេងទៀត តាមការតម្រូវរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

២- ត្រួតពិនិត្យការអនុវត្តការតម្រូវបមាណីយ ចំពោះផលិតផលថ្នាំកសិកម្មឬជីកសិកម្មដែលចេញពីប្រតិបត្តិការលាយផ្សំឬវេចខ្ចប់ជាថ្មី ដោយផ្ទៀតផ្ទាត់ជាមួយទិន្នន័យនិងព័ត៌មានដែលប្រតិបត្តិករបានអះអាងនៅពេលធ្វើការចុះបញ្ជី រួមមាន៖

- សំបកវេចខ្ចប់ និងស្លាកសញ្ញាព័ត៌មានជាភាសាខ្មែរ ដែលត្រូវអនុលោមតាមការតម្រូវបមាណីយ

- បមាណីយគុណភាពនៃផលិតផលថ្នាំកសិកម្មឬជីកសិកម្មដែលបានធ្វើការលាយផ្សំឬវេចខ្ចប់ជាថ្មី ដោយត្រូវដកយកសំណាកដើម្បីវិភាគផ្ទៀងផ្ទាត់បមាណីយដើមដែលបានអះអាង
- ការអនុវត្តការតម្រូវបមាណីយនិងវិធានសុវត្ថិភាពសម្រាប់ប្រតិបត្តិការលាយផ្សំឬវេចខ្ចប់ជាថ្មី
- ការអនុវត្តវិធានសុវត្ថិភាពសម្រាប់ឃ្លាំងសន្និធិ និងការអនុវត្តវិធានបច្ចេកទេសសម្រាប់ការធ្វើសន្និធិថ្នាំកសិកម្មឬជីកសិកម្ម ដែលចេញពីប្រតិបត្តិការលាយផ្សំឬវេចខ្ចប់ជាថ្មី
- វត្តមាននិងការទទួលខុសត្រូវរបស់បុគ្គលិកបច្ចេកទេសប្រចាំការនៅគ្រឹះស្ថានលាយផ្សំឬវេចខ្ចប់ជាថ្មី និងនៅក្នុងឃ្លាំងសន្និធិផលិតផលថ្នាំកសិកម្មឬជីកសិកម្ម។

## ផ្នែកទី៤៖ នីតិវិធីត្រួតពិនិត្យដើមគ្រាលើផលិតផលនាំចេញ

**ប្រការ ១៧.-**

ប្រតិបត្តិករដែលស្នើសុំលិខិតអនុញ្ញាតនាំចេញថ្នាំកសិកម្មឬជីកសិកម្ម មានកាតព្វកិច្ចធ្វើលិខិតប្រតិវេទន៍ជូននាយកដ្ឋាននីតិកម្មកសិកម្ម អំពីការនាំចេញផលិតផលថ្នាំកសិកម្មឬជីកសិកម្មពីឃ្លាំងអចិន្ត្រៃយ៍របស់ប្រតិបត្តិករ នៅក្នុងរយៈពេលយ៉ាងតិច ៤៥ (សែសិបប្រាំ)ថ្ងៃ មុនកាលបរិច្ឆេទនាំចេញ។

នាយកដ្ឋាននីតិកម្មកសិកម្ម ត្រូវចាត់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមានសមត្ថកិច្ចនៅក្នុងរយៈពេលមិនលើសពី ៥ (ប្រាំ)ថ្ងៃ ដោយគិតចាប់ពីថ្ងៃទទួលលិខិតប្រតិវេទន៍ ដើម្បីចុះធ្វើការត្រួតពិនិត្យដើមគ្រាចំពោះផលិតផលថ្នាំកសិកម្មឬជីកសិកម្ម ដែលប្រតិបត្តិករស្នើសុំធ្វើការនាំចេញជាក់ស្តែង។

រយៈពេលនៃការត្រួតពិនិត្យដើមគ្រាសម្រាប់ថ្នាំកសិកម្មឬជីកសិកម្មនាំចេញ មិនត្រូវបានរាប់បញ្ចូលក្នុងដំណើរការពិនិត្យសម្រេចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លើការស្នើសុំលិខិតអនុញ្ញាតនាំចេញថ្នាំកសិកម្មឬជីកសិកម្មនោះឡើយ។

**ប្រការ ១៨.-**

រាល់ផលិតផលថ្នាំកសិកម្មឬជីកសិកម្មដែលធ្វើការនាំចេញ ត្រូវធ្វើប្រតិវេទន៍ជាចាំបាច់សម្រាប់ការត្រួតពិនិត្យដើមគ្រាដោយមន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមានសមត្ថកិច្ច។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មិនផ្តល់លិខិតអនុញ្ញាតនាំចេញថ្នាំកសិកម្មឬជីកសិកម្មចំពោះប្រតិបត្តិករណាដែលខកខានឬចេតនាមិនធ្វើប្រតិវេទន៍អំពីការនាំចេញរបស់ខ្លួន និងមិនបានឆ្លងកាត់ការត្រួតពិនិត្យដើមគ្រា ដោយអនុលោមតាមនីតិវិធីនៃប្រកាសនេះឡើយ។

**ប្រការ ១៩.-**

នៅក្នុងការត្រួតពិនិត្យដើមគ្រា ចំពោះថ្នាំកសិកម្មឬជីកសិកម្មដែលស្នើសុំនាំចេញ មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមានសមត្ថកិច្ចមានសិទ្ធិនិងភារកិច្ច ដូចខាងក្រោម៖

១- ត្រួតពិនិត្យឯកសារពាក់ព័ន្ធ៖

- ពាក្យស្នើសុំលិខិតអនុញ្ញាតនាំចេញថ្នាំកសិកម្មឬជីកសិកម្ម
- លិខិតអនុញ្ញាតធ្វើប្រតិបត្តិការលាយផ្សំឬវេចខ្ចប់ជាថ្មីផលិតផលថ្នាំកសិកម្មឬជីកសិកម្មសម្រាប់ការនាំចេញ

- វិញ្ញាបនបត្របញ្ជាក់បញ្ជិកាផលិតផលថ្នាំកសិកម្មឬជីកសិកម្មដែលត្រូវធ្វើការនាំចេញ
- កិច្ចសន្យាផ្គត់ផ្គង់ផលិតផលថ្នាំកសិកម្មឬជីកសិកម្មសម្រាប់ការនាំចេញ និងឯកសារបញ្ជីទំនិញដែលស្នើនាំចេញ
- កំណត់ត្រាពាណិជ្ជកម្មថ្នាំកសិកម្មឬជីកសិកម្មប្រភេទ "គ" ស្តីពីប្រតិបត្តិការនាំចេញស្របតាមគំរូដែលដាក់ឲ្យប្រើប្រាស់
- ឯកសារពាក់ព័ន្ធផ្សេងទៀត តាមការតម្រូវរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

២- ត្រួតពិនិត្យការអនុវត្តការតម្រូវបមាណីយ ចំពោះផលិតផលថ្នាំកសិកម្មឬជីកសិកម្មដែលនាំចូល ដោយផ្ទៀតផ្ទាត់ជាមួយទិន្នន័យនិងព័ត៌មានដែលប្រតិបត្តិករបានអះអាងនៅពេលធ្វើការចុះបញ្ជី រួមមានៈ

- សំបកវេចខ្ចប់ និងស្លាកសញ្ញាព័ត៌មាន ដែលត្រូវអនុលោមតាមការតម្រូវបមាណីយ
- បមាណីយគុណភាពនៃផលិតផលថ្នាំកសិកម្មឬជីកសិកម្មដែលត្រូវនាំចេញ ដោយដកយកសំណាកដើម្បីវិភាគផ្ទៀងផ្ទាត់បមាណីយដើមដែលបានអះអាង
- ការអនុវត្តវិធានសុវត្ថិភាពសម្រាប់ឃ្លាំងសន្និធិ និងការអនុវត្តវិធានបច្ចេកទេសសម្រាប់ការធ្វើសន្និធិថ្នាំកសិកម្មឬជីកសិកម្ម
- វត្តមាននិងការទទួលខុសត្រូវរបស់បុគ្គលិកបច្ចេកទេសប្រចាំការនៅគ្រឹះស្ថាននាំចេញ និងនៅក្នុងឃ្លាំងសន្និធិផលិតផលថ្នាំកសិកម្មឬជីកសិកម្មរបស់ក្រុមហ៊ុន។

## ផ្នែកទី៥ ៖ នីតិវិធីបញ្ចប់ការត្រួតពិនិត្យដើមគ្រា

### ប្រការ ២០.-

នៅរាល់ប្រតិបត្តិការត្រួតពិនិត្យដើមគ្រាថ្នាំកសិកម្មឬជីកសិកម្ម មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមានសមត្ថកិច្ច ត្រូវធ្វើកំណត់ហេតុត្រួតពិនិត្យនិងបំពេញទម្រង់បែបបទពាក់ព័ន្ធ នៅក្នុងប្រតិបត្តិការត្រួតពិនិត្យ ដោយត្រូវអានឲ្យប្រតិបត្តិករសាមីបានជ្រាបដោយផ្ទាល់ ដើម្បីចុះហត្ថលេខាឬផ្តិតស្នាមម្រាមដៃទទួលស្គាល់លទ្ធផលនៃការត្រួតពិនិត្យ។

### ប្រការ ២១.-

ក្នុងករណីលទ្ធផលនៃការត្រួតពិនិត្យដើមគ្រា ត្រូវបានរកឃើញកំហុសរបស់ប្រតិបត្តិករដែលល្មើសនឹងច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនិងបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមានសមត្ថកិច្ចមានសិទ្ធិចាត់វិធានការដូចខាងក្រោមៈ

(១)- ផ្អាកជាបណ្តោះអាសន្នការផ្គត់ផ្គង់ចែកចាយ ឬផ្អាកការធ្វើចរាចរណ៍ផលិតផលថ្នាំកសិកម្មឬជីកសិកម្មចេញពីឃ្លាំងអចិន្ត្រៃយ៍របស់ប្រតិបត្តិករ។

(២)- ដកហូតជាបណ្តោះអាសន្នលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្មឬជីកសិកម្ម និងលិខិតអនុញ្ញាតពាក់ព័ន្ធផ្សេងទៀត។

(៣)- ចាប់យកវត្ថុតាង និងបិទស្លាកបោះត្រាលើវត្ថុតាង។

(៤)- តម្រូវឲ្យប្រតិបត្តិករប្រមូលបញ្ចូលឃ្លាំងវិញ នូវផលិតផលថ្នាំកសិកម្មឬជីកសិកម្មដែលបានចរាចរលើទីផ្សារ ក្នុងករណីការផ្តល់សុពលភាពផ្គត់ផ្គង់ចែកចាយត្រូវបានបដិសេធដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

(៥)- ចាត់វិធានការពិន័យអន្តរការណ៍ ឬដោះស្រាយបទល្មើសស្របតាមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មជាធរមាន។

(៦)- ចងក្រងសំណុំរឿងនៃបទល្មើសដើម្បីបញ្ជូនទៅតុលាការតាមនីតិវិធី។

(៧)- ចាត់វិធានការផ្សេងទៀតស្របតាមច្បាប់ជាធរមាន។

**ប្រការ ២២.-**

នៅក្រោយពេលបញ្ចប់ប្រតិបត្តិការត្រួតពិនិត្យដើមគ្រា មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមានសមត្ថកិច្ច ត្រូវធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរជូនប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ក្នុងរយៈពេលមិនលើសពី **១០** (ដប់)ថ្ងៃ ដោយគិតចាប់ពីថ្ងៃបញ្ចប់ការងារត្រួតពិនិត្យដើមគ្រា។

នាយកដ្ឋាននីតិកម្មកសិកម្មត្រូវសរុបរបាយការណ៍ត្រួតពិនិត្យដើមគ្រា ដើម្បីស្នើសុំក្រសួងពិនិត្យសម្រេចផ្តល់សុពលភាពផ្គត់ផ្គង់ចែកចាយ ក្នុងរយៈពេលមិនលើសពី **៥** (ប្រាំ)ថ្ងៃ ដោយគិតចាប់ពីថ្ងៃទទួលរបាយការណ៍ត្រួតពិនិត្យដើមគ្រា។

**ប្រការ ២៣.-**

លទ្ធផលនៃការវិភាគសំណាកថ្នាំកសិកម្មឬជីកសិកម្ម ដែលបានដកយកនៅក្នុងប្រតិបត្តិការត្រួតពិនិត្យដើមគ្រា ត្រូវបញ្ជូនមកនាយកដ្ឋាននីតិកម្មកសិកម្មវិញ ដើម្បីដាក់បញ្ចូលក្នុងសំណុំរឿងតាមករណីដែលបានត្រួតពិនិត្យ។

ក្នុងករណីលទ្ធផលនៃការវិភាគសំណាកបានបង្ហាញភាពមិនអនុលោមនៃសមាសភាពនិងបមាណីយគុណភាពផលិតផលថ្នាំកសិកម្មឬជីកសិកម្មដែលបានត្រួតពិនិត្យ ឬក្នុងករណីប្រតិបត្តិករប្រព្រឹត្តល្មើសនឹងនីតិវិធីជាធរមាន ដូចបានចុះក្នុងកំណត់ហេតុត្រួតពិនិត្យ នាយកដ្ឋាននីតិកម្មកសិកម្មត្រូវកោះអញ្ជើញសាមីប្រតិបត្តិករដើម្បីមកដោះស្រាយបទល្មើសស្របតាមនីតិវិធី។

ក្នុងករណីសាមីប្រតិបត្តិករខកខានមិនមកដោះស្រាយបទល្មើសតាមលិខិតកោះអញ្ជើញ ទោះជាដោយមានមូលហេតុណាមួយក្តី ឬចេតនាមិនដោះស្រាយបទល្មើស នាយកដ្ឋាននីតិកម្មកសិកម្មត្រូវបញ្ជូនសំណុំរឿងករណីបទល្មើសទៅសាលាដំបូងរាជធានីឬខេត្តសាមីស្របតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយត្រូវចុះក្នុងកំណត់ត្រានូវឈ្មោះប្រតិបត្តិករដែលមិនអនុវត្តច្បាប់ទាំងនោះ ដើម្បីមានវិធានការចំពោះសំណើសុំធ្វើប្រតិបត្តិការពាក់ព័ន្ធថ្មីបន្ថែមទៀត នៅពេលខាងមុខ។

## ផ្នែកទី៦៖ ការផ្តល់សុពលភាពផ្គត់ផ្គង់ចែកចាយ

**ប្រការ ២៤.-**

ដោយផ្អែកតាមសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លើការផ្តល់សុពលភាពផ្គត់ផ្គង់ចែកចាយ នាយកដ្ឋាននីតិកម្មកសិកម្ម ត្រូវជូនដំណឹងជាលាយល័ក្ខណ៍អក្សរ ដល់

ប្រតិបត្តិករសាមី អំពីការផ្តល់សុពលភាពផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្មឬជីកសិកម្ម នៅក្នុងរយៈពេល ២(ពីរ) ថ្ងៃ ដោយគិតចាប់ពីកាលបរិច្ឆេទទទួលសេចក្តីសម្រេចផ្តល់សុពលភាពផ្គត់ផ្គង់ចែកចាយ ។

នាយកដ្ឋាននីតិកម្មកសិកម្ម អាចជូនដំណឹងដោយផ្ទាល់មាត់ជាមុនចំពោះប្រតិបត្តិករពាក់ព័ន្ធ ស្តីពីការផ្តល់សុពលភាពផ្គត់ផ្គង់ចែកចាយផលិតផលថ្នាំកសិកម្មឬជីកសិកម្ម តាមការចាំបាច់។

គំរូសេចក្តីជូនដំណឹងស្តីពីការផ្តល់សុពលភាពផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្មឬជីកសិកម្ម ត្រូវបានកំណត់នៅក្នុងឧបសម្ពន្ធទី៣នៃប្រកាសនេះ។

## ជំពូកទី៤
## ទោសប្បញ្ញត្តិ

**ប្រការ ២៥.-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលប្រព្រឹត្តល្មើស ឬមិនគោរពតាមនីតិវិធីនិងបទប្បញ្ញត្តិដូចមានចែងក្នុងប្រកាសនេះ ត្រូវទទួលទណ្ឌកម្មជាក់លាក់ដោយអនុលោមតាមទោសប្បញ្ញត្តិដូចមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម និងបទប្បញ្ញត្តិច្បាប់ពាក់ព័ន្ធផ្សេងទៀតជាធរមាន។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**ប្រការ ២៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ២៧.-**

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងប្រធានមន្ទីរកសិកម្មរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងខ្លួនៗ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ២០១៥

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**បណ្ឌិត អ៊ុក រ៉ាប៊ុន**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុ
- ក្រសួងយុត្តិធម៌
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ២៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ពន្ធទី១ នៃប្រកាសលេខ...០៩៩...........ប្រក.កសក ចុះថ្ងៃទី...០៤....ខែ...តុលា...........ឆ្នាំ២០១៥

ស្ដីពី "នីតិវិធីនៃការត្រួតពិនិត្យដើមគ្រានិងការផ្ដល់សុពលភាពផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្មឬជីកសិកម្ម"

## គំរូលិខិតប្រតិវេទន៍លើប្រតិបត្តិការពាក់ព័ន្ធនឹងថ្នាំកសិកម្មឬជីកសិកម្ម

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## លិខិតប្រតិវេទន៍
## សម្រាប់ការត្រួតពិនិត្យដើមគ្រាផលិតផលថ្នាំកសិកម្មឬជីកសិកម្ម

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ....................................ជាអក្សរឡាតាំង....................................

មុខងារ...........................................ក្រុមហ៊ុន...........................................................................

អាសយដ្ឋាន...................................................................................................................

.....................................................................លេខទំនាក់ទំនង..........................................

សូមធ្វើប្រតិវេទន៍ជូននាយកដ្ឋាននីតិកម្មកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទអំពីផលិតផលថ្នាំកសិកម្មឬជីកសិកម្មដែលក្រុមហ៊ុនបានធ្វើប្រតិបត្តិការ ☐នាំចូល ☐នាំចេញ ☐លាយផ្សំឬវេចខ្ចប់ជាថ្មី ដើម្បីមន្ត្រីមានសមត្ថកិច្ចចុះត្រួតពិនិត្យដើមគ្រា ដែលមានដូចខាងក្រោម៖

ក-លិខិតអនុញ្ញាតលេខ..................................ចុះថ្ងៃទី..........ខែ.......................ឆ្នាំ............

.....................................................................................................................................

ខ-យថាប្រភេទ ៖ ☐ថ្នាំកសិកម្ម ☐ជីកសិកម្ម ☐បញ្ជីភ្ជាប់(ករណីច្រើនមុខ)

១-...................................................................................................................................

២-...................................................................................................................................

៣-...................................................................................................................................

៤-...................................................................................................................................

៥-.................................................................................................................................។

គ-បរិមាណសរុបតាមលិខិតអនុញ្ញាត៖ ចំនួន..................មុខ បរិមាណ...........................តោន

.....................................................................................................................................

ឃ-ទីកន្លែងត្រូវត្រួតពិនិត្យ៖ ឃ្លាំងសន្និធិអចិន្ត្រៃយ៍ដែលមានអាសយដ្ឋាន៖

១-...............................................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

ង-ប្រភេទនិងអត្តសញ្ញាណមធ្យោបាយដឹកជញ្ជូន៖.................................................................................

ចំនួន..........................គ្រឿង ផ្ទុកបរិមាណ.........................................................../គ្រឿង។

ច-មាត់ច្រកឬផែដែលត្រូវធ្វើប្រតិបត្តិការនាំចូលនាំចេញ៖.................................................................

.......................................................................................................................................

ឆ-កាលបរិច្ឆេទត្រូវត្រួតពិនិត្យ៖ ថ្ងៃទី.........ខែ............ឆ្នាំ............ដល់ថ្ងៃទី........ខែ..........ឆ្នាំ......

អាស្រ័យដូចបានជម្រាបជូនខាងលើ ខ្ញុំសូមលោកប្រធាននាយកដ្ឋាននីតិកម្មកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មេត្តាជ្រាប និងពិនិត្យសម្រេចតាមការគួរ ដោយក្តីអនុគ្រោះ។

រាជធានីភ្នំពេញ ថ្ងៃទី...........ខែ.....................ឆ្នាំ.............

**នាយកក្រុមហ៊ុន**

# ឧបសម្ព័ន្ធទី២

នៃប្រកាសលេខ......០៩៩..........................ប្រក.កសក

ចុះថ្ងៃទី....០៤.........ខែ...កុម្ភៈ...................ឆ្នាំ២០១៥...

ស្តីពី "នីតិវិធីនៃការត្រួតពិនិត្យដើមគ្រា និងការផ្តល់សុពលភាពផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្មឬជីកសិកម្ម"

# គំរូកំណត់ត្រាពាណិជ្ជកម្មថ្នាំកសិកម្ម ឬជីកសិកម្ម

## ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
## នាយកដ្ឋាននីតិកម្មកសិកម្ម

# កំណត់ត្រា
# ពាណិជ្ជកម្មថ្នាំកសិកម្ម
# ឬជីកសិកម្ម
## ប្រភេទ "ក"
# ប្រតិបត្តិការនាំចូល

សម្រាប់ក្រុមហ៊ុន ៖ ..................................................................

ឃ្លាំងអចិន្ត្រៃយ៍ ៖ ..................................................................

..................................................................

# អត្តសញ្ញាណរបស់ប្រតិបត្តិករ

## Identification of Operator

១- ឈ្មោះប្រតិបត្តិករ ៖ ..........................................................................................

២- ថ្ងៃខែឆ្នាំកំណើត ៖ ..............................................................សញ្ជាតិ.............

៣- អត្តសញ្ញាណប័ណ្ណឬលិខិតឆ្លងដែនលេខ៖ ..........................................................

៤- មុខងារ ៖ ..........................................................................................................

៥- ក្រុមហ៊ុន ឬនីតិបុគ្គល ៖ ......................................................................................

៦- អាសយដ្ឋាននៅកម្ពុជា ៖ ......................................................................................

..........................................................................................................................

ទូរស័ព្ទ ទូរសារ (Phone/Fax)...................................................................................

អ៊ីម៉ែល (Email)......................................................................................................

គេហទំព័រ (Website) ...............................................................................................

៧- ចុះបញ្ជីពាណិជ្ជកម្ម ឬចុះបញ្ជីនីតិបុគ្គលផ្សេងទៀត

លេខ..............................ចុះថ្ងៃទី..........ខែ.......................ឆ្នាំ..........

ចេញដោយ..............................................................................................................

៨- អត្តសញ្ញាណក្រុមហ៊ុនមេ ឬក្រុមហ៊ុនប្រភពដើមផលិតលាយផ្សំឬវេចខ្ចប់ជាថ្មី នៃប្រទេសនាំចេញ ៖

ក្រុមហ៊ុន ៖ .............................................................................................................

អាសយដ្ឋាន ៖ ..........................................................................................................

..........................................................................................................................

ទូរស័ព្ទ ទូរសារ (Phone/Fax)...................................................................................

អ៊ីម៉ែល (Email)......................................................................................................

គេហទំព័រ (Website) ...............................................................................................

៩- គោលបំណងប្រតិបត្តិការ ៖ ☐ នាំចូល ☐ ផ្គត់ផ្គង់ចែកចាយ

១០-ទីតាំងនិងសមត្ថភាពស្តុករបស់ឃ្លាំងសន្និធិ ៖

..........................................................................................................................

..........................................................................................................................

..........................................................................................................................

១១-បុគ្គលិកបច្ចេកទេសប្រចាំការ ៖ ឈ្មោះ.............................................................

..........................................................................................................................

..........................................................................................................................

# សម្រាប់ជីកសិកម្ម

# កំណត់ត្រាប្រតិបត្តិការនាំចូល

| លរ. | កាលបរិច្ឆេទ នាំចូល | លិខិតអនុញ្ញាត នាំចូលនិង កាលបរិច្ឆេទ | ប្រទេស ដើមនាំចេញ | មធ្យោបាយ | មាត់ច្រក | ប្រភេទ-យថាប្រភេទ | ឯកតា | បរិមាណ | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | ក្នុងលិខិត អនុញ្ញាត | នាំចូលជាក់ស្តែង | ផ្គត់ផ្គង់ ចែកចាយ | សល់សន្និធិ |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |

| លរ. | កាលបរិច្ឆេទ<br>នាំចូល | លិខិតអនុញ្ញាត<br>នាំចូលនិង<br>កាលបរិច្ឆេទ | ប្រទេស<br>ដើមនាំចេញ | មធ្យោបាយ | មាត់ច្រក | ប្រភេទ-យថាប្រភេទ | ឯកតា | បរិមាណ | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | ក្នុងលិខិត<br>អនុញ្ញាត | នាំចូលជាក់ស្តែង | ផ្គត់ផ្គង់<br>ចែកចាយ | សល់សន្និធិ |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |

**បានឃើញនិងឯកភាព**
**នាយកក្រុមហ៊ុន**

ថ្ងៃទី.............ខែ...................ឆ្នាំ..............
**បុគ្គលិកកត់ត្រារបស់ក្រុមហ៊ុន**

# កំណត់សម្គាល់របស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម
# នៅក្នុងការត្រួតពិនិត្យដើមគ្រា

លិខិតបញ្ជាបេសកកម្មលេខ..................................ចុះថ្ងៃទី..........ខែ.................ឆ្នាំ................
មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមាននីតិសម្បទាជានគរបាលយុត្តិធម៌ ដឹកនាំបេសកកម្ម
ឈ្មោះ........................................................ឋានៈ.........................................................
កំណត់សម្គាល់លើលទ្ធផលនៃការត្រួតពិនិត្យដើមគ្រា៖
.....................................................................................................................
.....................................................................................................................
.....................................................................................................................
.....................................................................................................................
.....................................................................................................................
.....................................................................................................................
.....................................................................................................................
.....................................................................................................................
.....................................................................................................................
.....................................................................................................................
.....................................................................................................................
.....................................................................................................................
.....................................................................................................................
.....................................................................................................................
.....................................................................................................................
.....................................................................................................................
.....................................................................................................................
.....................................................................................................................
.....................................................................................................................

កាលបរិច្ឆេទត្រួតពិនិត្យដើមគ្រា ៖.......................................................................

ហត្ថលេខាមន្ត្រីដឹកនាំបេសកកម្ម ៖.......................................................................

ឈ្មោះមន្ត្រីដឹកនាំបេសកកម្ម ៖.......................................................................

# សម្រាប់ថ្នាំកសិកម្ម

# កំណត់ត្រាប្រតិបត្តិការនាំចូល

| លរ. | កាលបរិច្ឆេទនាំចូល | លិខិតអនុញ្ញាតនាំចូលនិងកាលបរិច្ឆេទ | ប្រទេសដើមនាំចេញ | មធ្យោបាយ | មាត់ច្រក | ប្រភេទ-យថាប្រភេទ | ឯកតា | បរិមាណ | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | ក្នុងលិខិតអនុញ្ញាត | នាំចូលជាក់ស្តែង | ផ្គត់ផ្គង់ចែកចាយ | សល់សន្និធិ |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |

| ល.រ. | កាលបរិច្ឆេទនាំចូល | លិខិតអនុញ្ញាតនាំចូលនិងកាលបរិច្ឆេទ | ប្រទេសដើមនាំចេញ | មធ្យោបាយ | មាត់ច្រក | ប្រភេទ-យថាប្រភេទ | ឯកតា | បរិមាណ | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | ក្នុងលិខិតអនុញ្ញាត | នាំចូលជាក់ស្តែង | ផ្គត់ផ្គង់ចែកចាយ | សល់សន្និធិ |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |

ថ្ងៃទី.............ខែ...................ឆ្នាំ..............

**តំណាងក្រុមហ៊ុន**

# កំណត់សម្គាល់របស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម
# នៅក្នុងការត្រួតពិនិត្យដើមគ្រា

លិខិតបញ្ជាបេសកកម្មលេខ..............................ចុះថ្ងៃទី..........ខែ...................ឆ្នាំ...............

មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមាននីតិសម្បទាជានគរបាលយុត្តិធម៌ ដឹកនាំបេសកកម្ម

